**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧-០០៦-១០១ ប្រ.ក

ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ2006

**ប្រកាស**

**ស្តីពី**

**ការដាក់ឱ្យអនុវត្តនូវគោលការណ៍ណែនាំរបស់**

**ប្រព័ន្ធចែករំលែកព័ត៌មានឥណទាន**

**ទេសាភិបាលធនាគារជាតិនៃកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៤៤ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៤ ស្តីពីការតែងតាំងឯកឧត្តម **ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា មានឋានៈស្មើទេសរដ្ឋមន្ត្រី
- តាមស្មារតីអង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជានៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៦

**ស ំ រេ ច**

**ប្រការ ១.-**

ដាក់ឱ្យប្រើប្រាស់នូវគោលការណ៍ណែនាំសំរាប់ការគ្រប់គ្រងលើប្រព័ន្ធចែករំលែកព័ត៌មានឥណទានដែលមានខ្លឹមសារដូចមានចែងក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ ។

**ប្រការ ២.-**

អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាព គ្រប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ នៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ៣.-**

ប្រកាសនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០៦

**ទេសាភិបាល**

ជា ចាន់តូ

**កន្លែងទទួល :**

- ដូចប្រការ២ "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ

**ចម្លងជូន :**

- សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាបជាព័ត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីចុះក្នុងរាជកិច្ច"

# ឧបសម្ព័ន្ធទី១ នៃប្រកាសស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំរបស់ប្រព័ន្ធចែករំលែកព័ត៌មានឥណទាន

# គោលការណ៍ណែនាំ

# ការគ្រប់គ្រងប្រព័ន្ធចែករំលែកព័ត៌មានឥណទាន

## I- គោលបំណង

គោលការណ៍ណែនាំការគ្រប់គ្រងនេះ តទៅនេះហៅថា "**គោលការណ៍ណែនាំ**" មានគោលបំណងដាក់ចេញវិធានគ្រប់គ្រងរបៀបរបបធ្វើការងាររបស់ទីភ្នាក់ងារនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ដែលបង្កើតឡើងតាមបញ្ញត្តិនៃប្រកាសស្តីពីការប្រើប្រាស់ និងការការពារព័ត៌មានឥណទាន តទៅនេះហៅថា "**ប្រកាស**" ។

## II- ភាគីដែលអាចអនុវត្តបាន

គោលការណ៍ណែនាំនេះអនុវត្តបានចំពោះក្រុមប្រឹក្សាភិបាល គណៈកម្មាធិការគ្រប់គ្រង និងក្រុមប្រតិបត្តិនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ។

## III- ក្រុមប្រឹក្សាភិបាលប្រព័ន្ធចែករំលែកព័ត៌មានឥណទាន

ការិយាល័យរបស់ក្រុមប្រឹក្សាភិបាលនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ត្រូវស្ថិតនៅធនាគារជាតិនៃកម្ពុជា ។

១- ក្រុមប្រឹក្សាភិបាលនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទានរួមមាន ប្រធាន ១រូប និងសមាជិកពី ៦ ទៅ ៨រូប មកពីធនាគារជាសមាជិក និងទីភ្នាក់ងារ ។

២- ធនាគារជាតិនៃកម្ពុជាត្រូវចាត់តាំងប្រធានក្រុមប្រឹក្សាភិបាលនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទានឱ្យធ្វើជាតំណាង និងទទួលបន្ទុកប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ។

៣- ប្រធានក្រុមប្រឹក្សាភិបាលនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទានត្រូវតែងតាំងនាយក ។ ប៉ុន្តែច្រើនជាងមួយភាគបីនៃនាយកទាំងអស់ត្រូវតែងតាំងបេក្ខជនមកពីធនាគារជាសមាជិក ។

៤- ប្រធានក្រុមប្រឹក្សាភិបាលនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទានត្រូវតែងតាំងប្រធានគណៈកម្មាធិការគ្រប់គ្រង ប្រធានដឹកនាំក្រុមប្រតិបត្តិ និងសមាជិកប្រព័ន្ធចែករំលែកព័ត៌មានឥណទានផ្សេងទៀត ។

៥- ប្រធានគណៈកម្មាធិការគ្រប់គ្រងត្រូវតែជាសមាជិកនៃក្រុមប្រឹក្សាភិបាលនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទានដោយស្វ័យប្រវត្តិ ។ នៅពេលប្រធានក្រុមប្រឹក្សាភិបាលនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទានអវត្តមាន ប្រធានគណៈកម្មាធិការគ្រប់គ្រងជាអ្នកដឹកនាំជំនួស ។

៦- តំណែងប្រធានក្រុមប្រឹក្សាភិបាលនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទានមានអាណត្តិ ២ឆ្នាំ ហើយអាចតែងតាំងជាថ្មីបាន ។

៧- ការប្រជុំរបស់ក្រុមប្រឹក្សាភិបាលនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទាន អាចប្រព្រឹត្តទៅបានដោយមានវត្តមានសមាជិកពាក់កណ្តាល ឬច្រើនជាងនេះនៃសមាជិកក្នុងបញ្ជី និងសំរេចចិត្តដោយមតិភាគច្រើន (ចាប់ពីពាក់កណ្តាល ឬច្រើនជាងនេះ) នៃចំនួនសមាជិកដែលមានវត្តមាន ។ ក្នុងករណីមានសម្លេងស្មើគ្នា សម្លេងរបស់ប្រធានមានឧត្តមភាព ។

៨- ក្រុមប្រឹក្សាភិបាលនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ត្រូវមើលការខុសត្រូវលើប្រតិបត្តិការ និងការអនុវត្តន៍របស់ទីភ្នាក់ងារ ដើម្បីធានាសុវត្ថិភាពមូលដ្ឋានទិន្នន័យព័ត៌មានឥណទាន ប្រសិទ្ធភាព និងភាពសមរម្យនៃវិធានការរបស់ទីភ្នាក់ងារ និងការអនុវត្តន៍តាមក្រមប្រតិបត្តិរបស់សមាជិក ។

៩- ក្រុមប្រឹក្សាភិបាលនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ត្រូវចាត់វិធានការចំពោះការប្រព្រឹត្តិល្មើសនឹងប្រកាស និងក្រមប្រតិបត្តិ តាមរយៈការត្រួតពិនិត្យទៀងទាត់ និង/ឬ តាមរយៈការត្រួតពិនិត្យពិសេស ។

១០- បន្ទាប់ពីទទួលបានការយល់ព្រមលើកាលកំណត់ដំបូង (ឧបសម្ព័ន្ធនៃគោលការណ៍ណែនាំនេះ) ពីធនាគារជាតិនៃកម្ពុជា ក្រុមប្រឹក្សាភិបាលនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទានត្រូវរៀបចំ និងចេញប្រកាសពិន័យ និងកាលកំណត់បង់សងពិន័យ ក្នុងនាមប្រធានរបស់ខ្លួនចំពោះរាល់បទល្មើសបំពានលើប្រកាស និងក្រមប្រតិបត្តិ ។ ក្រុមប្រឹក្សាភិបាលនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទាន អាចកែប្រែការដាក់ពិន័យ និងកាលកំណត់បង់សងពិន័យបាន ។ ការពិន័យ និងកាលកំណត់បង់សងពិន័យ ដែលក្រុមប្រឹក្សាភិបាលនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទានកែប្រែថ្មី មានប្រសិទ្ធភាពដូចកាលកំណត់ដំបូងដែលធនាគារជាតិនៃកម្ពុជាបានយល់ព្រមដែរ ហើយត្រូវជូនដំណឹងដល់ធនាគារជាសមាជិកភ្លាមៗ ។

## IV- បញ្ហាសំរាប់ការពិគ្រោះយោបល់របស់ក្រុមប្រឹក្សាភិបាលនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទាន

ក្រុមប្រឹក្សាភិបាលនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ត្រូវចេញសេចក្តីសំរេចចិត្តដោយពិគ្រោះយោបល់គ្នាចំពោះចំណុចមួយចំនួនខាងក្រោម :

១- បញ្ហាទាក់ទងនឹងប្រភេទព័ត៌មានឥណទានសំខាន់ៗ ដែលទីភ្នាក់ងារប្រមូលយក និងរយៈពេលរក្សាទុក និងកំរិតអប្បបរមា នៅក្រោមបញ្ញត្តិនៃប្រកាស និងក្រមប្រតិបត្តិដែលអាចយកមកអនុវត្តបាន

២- បញ្ហាទាក់ទងនឹងការទទួល/ការចែករំលែក និងការទូទាត់ចំណាយប្រតិបត្តិការដែលកើតឡើងក្នុងដំណើរការនៃការប្រមូលមជ្ឈការ ការគ្រប់គ្រង និងការប្រើប្រាស់ព័ត៌មានឥណទាន ដោយទីភ្នាក់ងារ និងការវិនិយោគលើគំរោងថ្មី

៣- បញ្ហាទាក់ទងនឹងការស៊ើបអង្កេត លក្ខខណ្ឌជាក់ស្តែងនៃការអនុវត្តន៍តាមភារកិច្ចនៃគ្រឹះស្ថានហិរញ្ញវត្ថុដើម្បីផ្តល់ព័ត៌មានឥណទាន និងដាក់ពិន័យ

៤- ចំណុចជាក់លាក់ចាំបាច់សំរាប់ប្រតិបត្តិការរបស់ប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ។

## V- គណៈកម្មាធិការគ្រប់គ្រង

១- គណៈកម្មាធិការគ្រប់គ្រងមានសមាសភាពពី ៣ ទៅ ១០ រូប ដោយមានប្រធាន ១រូប សមាជិកអចិន្ត្រៃយ៍យ៉ាងហោច ២រូប មកពីធនាគារជាតិនៃកម្ពុជា និងសមាជិកមិនអចិន្ត្រៃយ៍មកពី :

- នាយកចាត់ការនាយកដ្ឋានឥណទានរបស់ធនាគារជាសមាជិក
- តំណាងតែងតាំងដោយសមាគមធនាគារនៅកម្ពុជា
- បុគ្គលដទៃទៀតដែលប្រធានក្រុមប្រឹក្សាភិបាលនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទានបានស្នើឡើង ។

២- ប្រធានក្រុមប្រឹក្សាភិបាលនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ជាអ្នកតែងតាំងប្រធានគណៈ-កម្មាធិការគ្រប់គ្រង ។

៣- ប្រធានគណៈកម្មាធិការគ្រប់គ្រងមានអាណត្តិ ២ឆ្នាំ ហើយអាចតែងតាំងជាថ្មីបាន ។

៤- ប្រធានគណៈកម្មាធិការគ្រប់គ្រងជាអ្នកជ្រើសតាំងសមាជិក ប្រធានក្រុមប្រឹក្សាភិបាលនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទានជាអ្នកតែងតាំងប្រធាន ។

៥- ការប្រជុំគណៈកម្មាធិការគ្រប់គ្រងអាចកោះហៅ ឬតាមសំណើរបស់ប្រធានគណៈកម្មាធិការគ្រប់គ្រង តាមរយៈសំណើ ១ ភាគ ៣ ឬច្រើនជាងនេះនៃសមាជិកចុះបញ្ជី ក្នុងករណីចាំបាច់ ។

៦- ការប្រជុំគណៈកម្មាធិការគ្រប់គ្រងអាចប្រព្រឹត្តទៅបានដោយមានវត្តមានសមាជិកពាក់កណ្តាល ឬច្រើនជាងនេះនៃសមាជិកក្នុងបញ្ជី និងសំរេចចិត្តដោយមតិភាគច្រើនចាប់ពីពាក់កណ្តាល ឬច្រើនជាងនេះនៃសមាជិកដែលមានវត្តមាន ។

## VI- បញ្ហាសំរាប់ការប្រឹក្សាយោបល់របស់គណៈកម្មាធិការគ្រប់គ្រង

គណៈកម្មាធិការគ្រប់គ្រងរៀបចំផែនការ និងសំរេចចិត្តដោយការពិគ្រោះយោបល់គ្នា ចំពោះចំណុចមួយចំនួនខាងក្រោម:

១- បញ្ហាទាក់ទងនឹងប្រភេទព័ត៌មានឥណទានសំខាន់ៗ ដែលភ្នាក់ងារប្រមូលយក និងរយៈពេលរក្សាទុក និងកំរិតអប្បបរមា នៅក្រោមបញ្ញត្តិនៃប្រកាស និងក្រមប្រតិបត្តិដែលអាចយកមកអនុវត្តបាន (មុននឹងអនុវត្តផែនការ ត្រូវទាមទារឱ្យមានការយល់ព្រមពីក្រុមប្រឹក្សាភិបាលនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទានជាមុនសិន) ។

២- បញ្ហាទាក់ទងនឹងការទទួល ការចែករំលែក និងការទូទាត់ចំណាយប្រតិបត្តិការដែលកើតឡើងក្នុងដំណើរការនៃការប្រមូលមជ្ឈការ ការគ្រប់គ្រង និងការប្រើប្រាស់ព័ត៌មានឥណទានដោយទីភ្នាក់ងារ និងការវិនិយោគលើគំរោងថ្មី (មុននឹងអនុវត្តផែនការត្រូវទាមទារឱ្យមានការយល់ព្រមពីក្រុមប្រឹក្សាភិបាលនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទានជាមុនសិន) ។

៣- បញ្ហាទាក់ទងនឹងការស៊ើបអង្កេតលក្ខខណ្ឌជាក់ស្តែងនៃការអនុវត្តន៍តាមភារកិច្ចរបស់ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុជាសមាជិក ដើម្បីផ្តល់ព័ត៌មានឥណទាន និងដាក់ពិន័យ ( មុននឹងអនុវត្តផែនការត្រូវទាមទារឱ្យមានការយល់ព្រមពីក្រុមប្រឹក្សាភិបាលនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទានជាមុនសិន) ។

៤- បញ្ហាទាក់ទងនឹងវិធានការទប់ស្កាត់ ករណីប្រើប្រាស់ខុស និងការលេចចេញព័ត៌មានឥណទានសំរាប់ប្រើប្រាស់ក្នុងគោលបំណងផ្សេងពីប្រកាសអនុញ្ញាត ។

៥- ចំណុចជាក់លាក់ចាំបាច់សំរាប់ការប្រមូលមជ្ឈការ ការគ្រប់គ្រង និងការប្រើប្រាស់ព័ត៌មានឥណទាន និងការត្រួតពិនិត្យរបស់ក្រុមប្រតិបត្តិប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ។

## VII- កិច្ចការរបស់ប្រធានគណៈកម្មាធិការគ្រប់គ្រង

១- ប្រធានគណៈកម្មាធិការគ្រប់គ្រងជាតំណាងឱ្យគណៈកម្មាធិការគ្រប់គ្រង ជំនួសប្រធានក្រុមប្រឹក្សាភិបាលនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ពេលប្រធានក្រុមប្រឹក្សាភិបាលនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទានអវត្តមាន និងជាអ្នកដឹកនាំការងារប្រព័ន្ធចែករំលែកព័ត៌មានឥណទានប្រចាំថ្ងៃ ។

២- ប្រធានគណៈកម្មាធិការគ្រប់គ្រងត្រូវតែងតាំងលេខាប្រតិបត្តិ ១រូប ក្នុងចំណោមសមាជិកអចិន្ត្រៃយ៍ ដើម្បីជួយសំរួលសកម្មភាពរបស់គណៈកម្មាធិការគ្រប់គ្រង និងការប្រាស្រ័យទាក់ទងរវាងគណៈកម្មាធិការគ្រប់គ្រង និងក្រុមប្រតិបត្តិប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ។ លេខាប្រតិបត្តិត្រូវរាយការណ៍អំពីកំណត់ហេតុប្រជុំទៅឱ្យសមាជិកគណៈកម្មាធិការគ្រប់គ្រង ក៏ដូចជាទៅឱ្យតំណាងរបស់ធនាគារជាសមាជិក និងគ្រឹះស្ថានហិរញ្ញវត្ថុ ដែលចូលរួមផ្តល់ព័ត៌មានឥណទាន នៅពេលណាដែលពាក់ព័ន្ធ និងរក្សាទុកឯកសារដើម និងឯកសារពាក់ព័ន្ធ ។

៣- ប្រធានគណៈកម្មាធិការគ្រប់គ្រង ត្រូវជ្រើសតាំងអ្នកដឹកនាំក្រុមប្រតិបត្តិនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ១រូប ដើម្បីឱ្យប្រធានក្រុមប្រឹក្សាភិបាលនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទានអនុម័តយល់ព្រម តែងតាំង ។

៤- ប្រធានគណៈកម្មាធិការគ្រប់គ្រងត្រូវរៀបចំផែនការថវិកាប្រចាំឆ្នាំ ដោយមានជំនួយពីអ្នកដឹកនាំក្រុមប្រតិបត្តិ ដើម្បីដាក់ជូនប្រធានក្រុមប្រឹក្សាភិបាលប្រព័ន្ធចែករំលែកព័ត៌មានឥណទានអនុម័តយល់ព្រម ។

៥- ប្រធានគណៈកម្មាធិការគ្រប់គ្រងត្រូវរៀបចំរបាយការណ៍ប្រព័ន្ធចែករំលែកព័ត៌មានឥណទានប្រចាំឆ្នាំ ដោយមានជំនួយពីប្រធានក្រុមប្រតិបត្តិ ដើម្បីដាក់ជូនប្រធានក្រុមប្រឹក្សាភិបាលនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទានអនុម័តយល់ព្រម ។

៦- ប្រធានគណៈកម្មាធិការគ្រប់គ្រងត្រូវរៀបចំរបាយការណ៍ប្រចាំខែ និងរាយការណ៍ជូនប្រធានក្រុមប្រឹក្សាភិបាលនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ។

៧- ប្រធានគណៈកម្មាធិការគ្រប់គ្រងត្រូវរៀបចំក្រុមការងារពិសេសមួយ ដើម្បីអនុវត្តការពិគ្រោះយោបល់ប៉ុន្មានចំណុចខាងលើឱ្យមានប្រសិទ្ធភាព ។

## VIII- ក្រុមប្រតិបត្តិ

១- ប្រធានគណៈកម្មាធិការគ្រប់គ្រងត្រូវចាត់ចែង និងត្រួតពិនិត្យក្រុមប្រតិបត្តិប្រព័ន្ធចែករំលែកព័ត៌មានឥណទានដើម្បីគ្រប់គ្រងឱ្យមានប្រសិទ្ធភាពនូវសូហ្វវែរ (Software) និងហាតវែរ (Hardware) របស់ទីភ្នាក់ងារដែលចាំបាច់សំរាប់ប្រតិបត្តិការប្រព័ន្ធចែករំលែកព័ត៌មានឥណទានប្រចាំថ្ងៃ ។

២- សមាសភាពក្រុមប្រតិបត្តិប្រព័ន្ធចែករំលែកព័ត៌មានឥណទាន រួមមានប្រធានក្រុមអ្នកគ្រប់គ្រងសេវាតាមប្រព័ន្ធវេបសាយ (web service administrator) អ្នកគ្រប់គ្រងសេវាមូលដ្ឋានទិន្នន័យ (database service administrator) និងក្រុមជំនួយការគ្រប់គ្រង ។

៣- ប្រធានគណៈកម្មាធិការគ្រប់គ្រងត្រូវជ្រើសតាំងប្រធានក្រុមប្រតិបត្តិ ក្នុងចំណោមបុគ្គលិកការិយាល័យព័ត៌មានុសាស្ត្ររបស់ទីភ្នាក់ងារ ហើយប្រធានក្រុមប្រឹក្សាភិបាលប្រព័ន្ធចែករំលែកព័ត៌មានឥណទានជាអ្នកតែងតាំង ។

៤- ក្នុងនាមជាអ្នកគ្រប់គ្រងប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ប្រធានក្រុមប្រតិបត្តិត្រូវគ្រប់គ្រង និងត្រួតពិនិត្យប្រតិបត្តិការប្រចាំថ្ងៃរបស់ប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ដោយមានអ្នកគ្រប់គ្រងសេវាវេបសាយ និងអ្នកគ្រប់គ្រងសេវាមូលដ្ឋានទិន្នន័យជាជំនួយការ ។

៥- ក្នុងករណីដែលប្រព័ន្ធចែករំលែកព័ត៌មានឥណទានមានបញ្ហាខូចខាត ប្រធានក្រុមប្រតិបត្តិត្រូវអនុវត្តការស្តារជាបន្ទាន់ និងរាយការណ៍ជូនប្រធានគណៈកម្មាធិការគ្រប់គ្រងអំពីលទ្ធផលភ្លាមៗដែរ ។

៦- អ្នកគ្រប់គ្រងសេវាវេបសាយនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទាន មានតួនាទីដូចខាងក្រោម :

- រក្សា និងការពារ web server របស់ប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ដោយទប់ទល់នឹងវីរុស (virus) ដែលលួចចូលបំផ្លាញប្រព័ន្ធវេបសាយ (hacker) និងការបាក់បែកខូចខាតសំបកខាងក្រៅ
- គ្រប់គ្រងអត្តសញ្ញាណអ្នកប្រើប្រាស់ធនាគារ (Bank User IDs) ដោយអនុញ្ញាត ព្យួរ ឬលុបចោល និងឆ្លើយតបទូរសារ (e-mail) ជាមួយអ្នកប្រើប្រាស់ ក្នុងករណីមានបំរែបំរួលស្ថានភាពរបស់អ្នកប្រើប្រាស់
- ឆ្លើយតបនឹងសំនួររបស់ធនាគារជាសមាជិក

- ជូនដំណឹងដល់ធនាគារជាសមាជិក អំពីបំរែបំរួលការប្រើប្រាស់ប្រព័ន្ធចែករំលែកព័ត៌មានឥណទាន និងបំរែបំរួលបទប្បញ្ញត្តិទាក់ទងនឹងប្រព័ន្ធចែករំលែកព័ត៌មានឥណទាន
- ពិនិត្យលើកិច្ចការថែទាំទំព័រ សំណើឆែកឆេរ (Check Request Page) របស់អ្នកចុះបញ្ជីទិន្នន័យធនាគារ (Bank Data Registrant)
- ពិនិត្យលើបន្ទុកប្រព័ន្ធ (system load) និង សកម្មភាពរបស់អ្នកប្រើប្រាស់
- បង្កើតស្ថិតិដែលទាក់ទងនឹងការប្រើប្រាស់ប្រព័ន្ធពាក់ព័ន្ធ
- រក្សាឯកសារបំរុង (back up) តាមកាលកំណត់
- រៀបចំរបាយការណ៍ប្រចាំខែអំពីការប្រព្រឹត្តិខុសច្បាប់ និងបទប្បញ្ញត្តិ ដោយធនាគារជាសមាជិក និងរាយការណ៍ជូនប្រធានក្រុម
- រាយការណ៍រាល់សកម្មភាពសង្ស័យនៅក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទានជូនប្រធានក្រុម
- រក្សា និងកែសំរួលក្បួនប្រើប្រាស់ប្រព័ន្ធចែករំលែកព័ត៌មានឥណទាន (CIS user manuals) សំរាប់ធនាគារជាសមាជិក អ្នកចុះបញ្ជីទិន្នន័យធនាគារ និងអ្នកប្រើប្រាស់ធនាគារ និងក្បួនសំរាប់អ្នកគ្រប់គ្រងសេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ។

៧- អ្នកគ្រប់គ្រងសេវាមូលដ្ឋានទិន្នន័យប្រព័ន្ធចែករំលែកព័ត៌មានឥណទាន មានតួនាទីដូចខាងក្រោម :

- រក្សា និងការពារ web server របស់ប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ដោយទប់ទល់នឹងវីរុស (virus) ដែលលួចចូលបំផ្លាញប្រព័ន្ធរបស់សាយ (hacker) និងការបាក់បែកខូចខាតសំបកខាងក្រៅ
- រក្សាឯកសារ back up តាមកាលកំណត់
- រៀបចំឯកសារបំរុងបន្ទាន់ និង ទំរង់ការស្តារ
- ពិនិត្យតាមដានបន្ទុកប្រព័ន្ធ (system load) និង ផែនការសំរាប់តម្រូវការ HDD បន្ថែម
- រាយការណ៍រាល់សកម្មភាពជាប់សង្ស័យនៅក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទានជូនប្រធានក្រុម ។

## IX- **ការបញ្ចេញព័ត៌មាន**

ប្រភេទព័ត៌មានស្ថិតិដែលជាសមិទ្ធិផលនៃប្រតិបត្តិការប្រព័ន្ធចែករំលែកព័ត៌មានឥណទាន និងដែលអាចបញ្ចេញឱ្យធនាគារជាសមាជិក និងសាធារណជនដឹង ត្រូវកំណត់ដោយគណៈកម្មាធិការគ្រប់គ្រងតាមប្រកាស និងបទប្បញ្ញត្តិប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ។

X- **បទប្បញ្ញត្តិបន្ថែម**

១- គោលការណ៍ណែនាំរបស់ប្រព័ន្ធចែករំលែកព័ត៌មានឥណទានចូលជាធរមានចាប់ពីថ្ងៃ ខែមិថុនា ឆ្នាំ២០០៦ នេះតទៅ ។

២- ការពិន័យ និងកាលកំណត់បង់សងពិន័យនៅក្នុងឧបសម្ព័ន្ធនៃគោលការណ៍ណែនាំនេះចូលជាធរមានចាប់ពីពេលចុះហត្ថលេខានេះតទៅ ។

# ឧបសម្ព័ន្ធទី១ នៃប្រកាសស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំរបស់ ប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ការពិន័យ និងកាលកំណត់បង់សងពិន័យចំពោះការប្រព្រឹត្តខុសនឹងក្រមប្រតិបត្តិ

## ១- កាលកំណត់ដែលធនាគារជាសមាជិកត្រូវរាយការណ៍អំពីព័ត៌មានឥណទាន

| ចំណាត់ថ្នាក់ | កាលបរិច្ឆេទរាយការណ៍ |
|---|---|
| ១- ការចុះបញ្ជីព័ត៌មានបំណុលមិនទាន់សង | ថ្ងៃធ្វើការចុងក្រោយនៃខែ |
| ២- ការចុះបញ្ជីព័ត៌មានបំណុលដែលខកខានមិនបានសង | ថ្ងៃធ្វើការបន្ទាប់ បន្ទាប់ពីពេលដែលមូលប្បទានប័ត្រ ឬវិក័យប័ត្រត្រូវបានគេបដិសេធ ហើយប្រកាសជា "ការខាកខានមិនបានសងជាលើកចុងក្រោយ" |
| ៣- ការចុះបញ្ជីនៃការឱ្យរួចបំណុល | ថ្ងៃធ្វើការចុងក្រោយនៃខែ ដែលរកឃើញហេតុផលឱ្យរួចបំណុល |
| ៤- ការឆ្លើយតបនឹងសំណើសុំផ្ទៀងផ្ទាត់/កែតម្រូវ | ក្នុងរយៈពេល ៧ថ្ងៃ បន្ទាប់ពីទទួលសំណើសុំផ្ទៀងផ្ទាត់ |

## ២- កាលកំណត់ពិន័យក្នុងករណីពន្យារ និងលុបចោល ការឱ្យរួចបំណុលមិនត្រឹមត្រូវ និងការធ្វេសប្រហែស

| ប្រភេទ | លក្ខខណ្ឌវិនិច្ឆ័យ | ពិន័យ | កំណត់សំគាល់ |
|---|---|---|---|
| ១- ការពន្យារ ឬការលុបចោលព័ត៌មានបំណុលមិនទាន់សង បំណុលដែលខកខានមិនបានសង និងការឱ្យរួចបំណុល | ៣០ថ្ងៃ និងតិចជាង | ៤.០០០រៀល | ក្នុង១ករណី |
| | ៦០ថ្ងៃ និងតិចជាង | ៨.០០០រៀល | |
| | ១៨០ថ្ងៃ និងតិចជាង | ១២.០០០រៀល | |
| | លើសពី១៨០ថ្ងៃ | ១៦.០០០រៀល | |
| ២- ការឱ្យរួចបំណុលមិនត្រឹមត្រូវនៃព័ត៌មានឥណទានអវិជ្ជមាន | | ១០០.០០០រៀល | ក្នុង១ករណី |
| ៣- ការធ្វេសប្រហែសក្នុងការដោះស្រាយសំណើសុំផ្ទៀងផ្ទាត់/កែតម្រូវ | ៧ថ្ងៃនិងច្រើនជាង បន្ទាប់ពីទទួលបានសំណើសុំផ្ទៀងផ្ទាត់/កែតម្រូវ | ២០.០០០រៀល | ក្នុង១ករណី |
| | ១៤ថ្ងៃនិងច្រើនជាង បន្ទាប់ពីទទួលបានសំណើសុំផ្ទៀងផ្ទាត់/កែតម្រូវ | ៤០.០០០រៀល | |
| | ៣០ថ្ងៃនិងច្រើនជាង បន្ទាប់ពីទទួលបានសំណើសុំផ្ទៀងផ្ទាត់/កែតម្រូវ | ៨០.០០០រៀល | |

៣- ប្រធានក្រុមប្រឹក្សាភិបាលនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ត្រូវជូនដំណឹងអំពីការពិន័យដែលរំពឹងនឹងធ្វើដល់ធនាគារជាសមាជិកជាប្រចាំខែ ។ ធនាគារជាសមាជិកអាចសរសេរលិខិតបដិសេធការពិន័យរបស់ប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ដោយភ្ជាប់ឯកសារភស្តុតាងមកជាមួយ ក្នុងរយៈពេល ១៥ថ្ងៃ បន្ទាប់ពីទទួលបានការជូនដំណឹងពីប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ។

៤- ប្រព្រឹត្តិកម្មក្នុងថេរៈវេលានៃការអនុគ្រោះ : ក្នុងអំឡុងពេលនៃការសាកល្បងគំរោងប្រព័ន្ធចែករំលែកព័ត៌មានឥណទាន (២០០៦-២០០៧) បើចំនួនករណីពន្យារ និងលុបចោល (ប្រភេទ១ នៃចំនុចទី ២ នៃឧបសម្ព័ន្ធនេះ) តិចជាង ១០ ករណីក្នុងមួយខែ ត្រូវឱ្យរួចពីកាលកំណត់ពិន័យ ក្នុងចំនុចទី២នៃឧបសម្ព័ន្ធនេះ ។ បើចំនួនករណីពន្យារ និងលុបចោលលើសពី ១០ ករណី នោះចំនួន ១០ ករណីត្រូវដកចេញពីចំនួនករណីសរុបក្នុងការគណនាចំនួនពិន័យ ។